E404

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 05 / 2016
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

**អង្គជំនុំជម្រះសាលាដំបូង**

ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **ការជូនដំណឹងអំពីការសិក្សាអដ្ឋិធាតុនៅជើងឯក និងការក្រើនរំលឹកទាក់ទងនឹងសំណើសុំនានាអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់យឺត**

១. នៅព្រឹកថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា បានផ្ញើសារអេឡិចត្រូនិកមួយមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងភាគី ដោយស្នើសុំឱ្យទទួលយកអត្ថបទមួយរបស់កាសែតភ្នំពេញប៉ុស្តិ៍ ដែលបានចុះផ្សាយនៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដើម្បីយកមកប្រើប្រាស់ក្នុងការសួរដេញដោលទៅសាក្សី 2-TCW-865 ដែលត្រូវបានកំណត់ពេលមកផ្តល់សក្ខីកម្មនៅថ្ងៃនោះដែរ។ មេធាវីការពារក្តីក៏បានស្នើសុំឱ្យទទួលយកផងដែរនូវ "របាយការណ៍កោសល្យវិច័យ" ស្តីពីឆ្អឹងលលាដ៍ក្បាលរបស់មនុស្សដែលបានរកឃើញនៅជើងឯក ដែលត្រូវបានយោងនៅក្នុងអត្ថបទនោះ។ ភាគីផ្សេងទៀតមិនបានជំទាស់ទៅនឹងការទទួលយកឯកសារនេះទេ ហើយសហព្រះរាជអាជ្ញាបានគាំទ្រដល់សំណើសុំស្វែងរក និងទទួលយក "របាយការណ៍កោសល្យវិច័យ"នេះ។ អង្គជំនុំជម្រះបានទទួលយកអត្ថបទកាសែត និងបានទទួលយកសំណើសុំឱ្យព្យាយាមស្វែងរកដើម្បីទទួលបានរបាយការណ៍នេះ ដោយកត់សម្គាល់ថា អង្គជំនុំជម្រះនឹងជូនដំណឹងភាគីនានា ពីលទ្ធ-

ផលនៃការខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះក្នុងការស្វែងរករបាយការណ៍នេះ ទៅតាមពេលវេលាដែលសមស្រប (ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៥៣ (សេចក្ដីព្រាង))។

២. ក្រឡាបញ្ជីអង្គជំនុំជម្រះបានទាក់ទងលោក វឿន វុទ្ធី ប្រធាននាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យានៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលទទួលបន្ទុកក្នុងការសិក្សានេះ។ លោក វឿន វុទ្ធី ជូនដំណឹងមកអង្គជំនុំជម្រះថា របាយការណ៍ដែលមានចំនួន ៣២ លេខ ជាភាសាខ្មែរ(“សៀវភៅសិក្សាពីជើងឯក”) ត្រូវបានមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯកផ្ដល់ជូន អ.វ.ត.ក នៅឆ្នាំ ២០១៤។ អង្គជំនុំជម្រះបានទាក់ទងកញ្ញា Julie Fleischman ជានិស្សិតថ្នាក់បណ្ឌិតដែលបានជួយដល់ក្រុមការងាររបស់លោក វឿន វុទ្ធី មួយផ្នែកនៅក្នុងការសិក្សាពីជើងឯក។ កញ្ញា Fleischman បង្ហាញថា សៀវភៅសិក្សាពីជើងឯកពុំមែនជារបាយការណ៍កោសល្យវិច័យទេ ដោយសារសៀវភៅនេះ មិនមែនធ្វើឡើងក្នុងគោលបំណងសម្រាប់កិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់ទេ។ ផ្ទុយទៅវិញសៀវភៅនេះ គឺជាការសិក្សាអំពីអដ្ឋិវិជ្ជា (ឆ្អឹង) ដោយផ្ដោតលើការប៉ះទង្គិចទៅលើឆ្អឹងលលាដ៍ក្បាល។ កញ្ញា Fleischman ក៏បានជូនដំណឹងមកអង្គជំនុំជម្រះថា គម្រោងសិក្សាមួយទៀតទៅលើអដ្ឋិធាតុនៅក្រាំងតាចាន់បានចាប់ផ្ដើមនៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ហើយរំពឹងថានឹងបញ្ចប់នៅក្នុងរយៈពេលពីរខែ។ អង្គជំនុំជម្រះក៏បានទាក់ទងលោកស្រី រស់ សុភាវ៉ារី អនុប្រធានមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ដើម្បីសាកសួរអំពីការផ្ដល់ជូនសៀវភៅសិក្សាពីជើងឯក។

៣. អង្គជំនុំជម្រះជូនដំណឹងដល់ភាគីថា លោកស្រី រស់ សុភាវ៉ារី បានផ្ដល់ជូនសៀវភៅសិក្សាពីជើងឯកចំនួនមួយឈុត (៣២ លេខ) មក អ.វ.ត.ក ដោយការបញ្ជូនដំបូងមានចំនួន ១២ លេខមកការិយាល័យរដ្ឋបាលនៅក្នុងឆ្នាំ ២០១៤។ សៀវភៅលេខដំបូងៗទាំងនេះ អាចរកបាននៅក្នុងបណ្ណាល័យ អ.វ.ត.ក ចាប់ពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ មក តែពុំមានសៀវភៅលេខទី៦ ទេ។ នាពេលនេះ អង្គជំនុំជម្រះបានទទួលសៀវភៅលេខផ្សេងទៀត (រួមទាំងលេខទី៦) ដែលត្រូវបានតម្កល់ទុកនៅទីតាំងជើងឯក។ នៅពេលនេះ សៀវភៅសិក្សាពីជើងឯកអាចរកបានដើម្បីយកមកពិនិត្យតែនៅក្នុងបណ្ណាល័យ អ.វ.ត.ក ប៉ុណ្ណោះ ដែលភាគីទាំងអស់អាចចូលទៅពិនិត្យមើលបាន។

៤. បន្ថែមពីលើនេះ “របាយការណ៍ស្ដីពីការវាយតម្លៃកម្មវិធីខាងក្រៅ” មួយទៅលើការសិក្សាពី

ជើងឯក ជាភាសាអង់គ្លេស និងភាសាខ្មែរ ("ការវាយតម្លៃ") អាចរកបាននៅបណ្ណាល័យ អ.វ.ត.ក ចាប់តាំងពីខែ កុម្ភៈ ឆ្នាំ ២០១៦ មក។ ការវាយតម្លៃនេះធ្វើការសង្ខេបនូវការរកឃើញពីការសិក្សានៅជើងឯក។ នាពេលនេះឯកសារនេះត្រូវបានថតស្កេន និងបញ្ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួមដែលមានលេខ ERN 01235378-01235427 ជាភាសាអង់គ្លេស និងលេខ ERN 01235428-01235506 ជាភាសាខ្មែរ។

៥. ផ្អែកលើព័ត៌មានថ្មីនេះ អង្គជំនុំជម្រះស្នើឱ្យភាគីនានាដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរចំពោះករណីថាតើ សៀវភៅសិក្សាពីជើងឯកគួរត្រូវបានទទួលយកជាឯកសារភស្តុតាង ឬ យ៉ាងណា បើគិតទៅដល់ចំនួនដ៏ច្រើនក្បាល ហើយអាចរកមើលបានតែជាភាសាខ្មែរប៉ុណ្ណោះ។ អង្គជំនុំជម្រះក៏ស្នើដល់ភាគីឱ្យដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរផងដែរស្តីពីភាពអាចទទួលយកបាននៃរបាយការណ៍វាយតម្លៃនេះ។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរមិនត្រូវឱ្យលើសពីចំនួន ១០ ទំព័រទេ ហើយត្រូវដាក់ត្រឹមថ្ងៃសុក្រ ទី ០៦ ខែ ឧសភា ដោយអនុលោមទៅតាមវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ អង្គជំនុំជម្រះក៏នឹងស្នើសុំឯកសារសិក្សាពីក្រាំងតាចាន់មួយឈុតដែរ នៅពេលដែលឯកសារនេះត្រូវបានបញ្ចប់រួចរាល់។

៦. អង្គជំនុំជម្រះសូមឆ្លៀតឱកាសនេះ ក្រើនរម្លឹកដល់ភាគីនានាថា សំណើសុំឱ្យទទួលយកជាឯកសារភស្តុតាងអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់យឺតយ៉ាវនឹងត្រូវបដិសេធ។ សំណើសុំឱ្យទទួលយកឯកសារដើម្បីយកមកប្រើប្រាស់សម្រាប់សួរដេញដោលសាក្សី ជាពិសេសតែមួយភាសា ដែលត្រូវបានដាក់កៀកពេលវេលាដែលសាក្សីនោះត្រូវបានកំណត់ពេលមកផ្តល់សក្ខីកម្មពេកនោះ ជាការដាក់សម្ពាធយ៉ាងអយុត្តិធម៌ដល់ភាគីផ្សេងទៀត និងអង្គជំនុំជម្រះ និងបង្ហាញពីកង្វះការយកចិត្តទុកដាក់ក្នុងការបំពេញការងាររបស់ភាគីដែលស្នើសុំ។ អង្គជំនុំជម្រះអនុគ្រោះចំពោះករណីនេះ ប៉ុន្តែអង្គជំនុំជម្រះនឹងមិនទទួលយកសំណើដែលបានដាក់យឺតយ៉ាវទៀតទេ នាពេលខាងមុខ ជាពិសេសក្នុងករណីដែលសំណើសុំទាំងនោះទាក់ទងទៅនឹងសម្ភារៈដែលអាចរកបានជាសាធារណៈ (ហើយនៅក្នុងករណីនេះ គឺមាននៅក្នុងបណ្ណាល័យ អ.វ.ត.ក) ជាយូរមកហើយ។